# អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ
# និង សហប្រតិបត្តិទាក់ទងនឹងសុំកូនអន្តរប្រទេស

## មាតិកា


ជំពូកទី ១ វិសាលភាពនៃអនុសញ្ញា ........................................................................

ជំពូកទី ២ លក្ខខណ្ឌតម្រូវសំរាប់សុំកូនអន្តរប្រទេស........................................................

ជំពូកទី ៣ អាជ្ញាធរមជ្ឈឹម (អាជ្ញាធរកណ្តាល) និងអង្គការដែលទទួលស្គាល់ជាផ្លូវការ ....................

ជំពូកទី ៤ លក្ខខណ្ឌផ្នែកនីតិវិធីសំរាប់សុំកូនអន្តរប្រទេស ..................................................

ជំពូកទី ៥ ការទទួលស្គាល់ និង ផលនៃសុំកូន.................................................................

ជំពូកទី ៦ បទប្បញ្ញត្តិទូទៅ ..........................................................................................

ជំពូកទី ៧ ខអវសាន .......................................................................................................

# អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ
# និង សហប្រតិបត្តិទាក់ទងនឹងសុំកូនអន្តរប្រទេស

សន្និសិទក្រុងឡាអេស្តីអំពីច្បាប់អន្តរជាតិនៅក្រុងឡាអេ ថ្ងៃទី ២៩ ឧសភា ១៩៩៣

## បុព្វកថា

រដ្ឋជាហត្ថលេខីនៃអនុសញ្ញានេះ

- ដោយទទួលស្គាល់ថាកុមារត្រូវចំរើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ នៅក្នុងបរិយាកាសនៃសុភមង្គល សេចក្តីស្រឡាញ់ និង កិត្តិយស សំរាប់ការចំរើនលូតលាស់ពេញលេញ និងយ៉ាងសុខដុម នៃបុគ្គលិកលក្ខណៈរបស់គេ
- ដោយរំលឹកឡើងវិញថារដ្ឋនីមួយៗ ជាអាទិភាពត្រូវចាត់វិធានការសមស្របដើម្បីឱ្យកុមារស្ថិតក្នុងការបីបាច់រក្សាពីសំណាក់គ្រួសារកំណើតរបស់គេ
- ដោយទទួលស្គាល់ថាសុំកូនអន្តរប្រទេសអាចផ្តល់អត្ថប្រយោជន៍នៃគ្រួសារអចិន្ត្រៃយ៍ដល់កុមារ ដោយសារគេមិនអាចរកគ្រួសារមួយសមស្របបាននៅក្នុងប្រទេសដើមរបស់កុមារនោះ
- ដោយជឿជាក់ថា ភាពចាំបាច់ក្នុងការចាត់វិធានការដើម្បីធានាថាសុំកូនអន្តរប្រទេសគឺធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារ និងដោយសេចក្តីគោរពសិទ្ធិមូលដ្ឋានរបស់កុមារ និងវិធានការណ៍ដើម្បីបង្កាការចាប់ពង្រត់ ការលក់ ឬ ជួញដូរកុមារ
- ដោយមានសេចក្តីប្រាថ្នាចង់បង្កើតបញ្ញត្តិរួមសំរាប់រឿងទាំងអស់នេះ ដោយពិចារណាដល់គោលការណ៍ចែងនៅក្នុងឧបករណ៍អន្តរជាតិ ជាពិសេសអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៩ និង សេចក្តីថ្លែងការណ៍នៃសហប្រជាជាតិស្តីពីគោលការណ៍សង្គម និង ច្បាប់ទាក់ទងនឹងការការពារសុខមាលភាពកុមារដែលយោង ជាពិសេសដល់ការដាក់ផ្ញើកុមារជាមួយគ្រួសារផ្សេងៗ និង សុំកូននៅក្នុងប្រទេស និងក្រៅប្រទេស (សេចក្តីសំរេចមហាសន្និបាតលេខ ៤១/៨៥ ចុះថ្ងៃ ៣ ធ្នូ ១៩៨៦)

បានព្រមព្រៀងគ្នាដូចតទៅនេះ :

## ជំពូក ១
## វិសាលភាពនៃអនុសញ្ញា

មាត្រា ១

ទិសដៅនៃអនុសញ្ញាគឺដើម្បី :

(ក)	កំណត់មធ្យោបាយការពារដើម្បីធានាថាសុំកូនអន្តរប្រទេសធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារ និងដោយសេចក្តីគោរពចំពោះសិទ្ធិមូលដ្ឋានរបស់កុមារដូចបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ ។

(ខ)	បង្កើតប្រព័ន្ធសហប្រតិបត្តិការក្នុងចំណោមរដ្ឋចុះហត្ថលេខាដើម្បីធានាថា មធ្យោបាយទាំងនោះត្រូវបានគោរព ហើយតាមរយៈប្រព័ន្ធនោះទប់ស្កាត់ ការពង្រាត់ ការលក់ ឬ ការជួញដូរកុមារ ។

(គ)	បានការទទួលស្គាល់នៅក្នុងរដ្ឋចុះហត្ថលេខាថាសុំកូនត្រូវប្រព្រឹត្តឡើងស្របតាមអនុសញ្ញានេះ ។

មាត្រា ២

១)	អនុសញ្ញានេះត្រូវអនុវត្តក្នុងករណីកុមារម្នាក់ជាជនមានទីលំនៅជាប្រចាំនៅក្នុងរដ្ឋចុះហត្ថលេខាមួយ (រដ្ឋដើម) ត្រូវបានកំពុងបាន ឬនឹងត្រូវបានយកទៅនៅរដ្ឋចុះហត្ថលេខាមួយទៀត (រដ្ឋទទួល) ក្រោយពីការសុំបានប្រព្រឹត្តទៅនៅក្នុងរដ្ឋដើមដោយសហព័ន្ធ ឬដោយជនម្នាក់ដែលមានទីលំនៅជាប្រចាំនៅក្នុងរដ្ឋទទួលក្តី ឬក្នុងគោលបំណងសុំកូននៅក្នុងរដ្ឋទទួលក្តី ឬរដ្ឋដើមក្តី ។

២)	អនុសញ្ញានេះគ្របដណ្តប់តែលើសុំកូនទាំងឡាយណា ដែលបង្កើតទំនាក់ទំនងជា ឪពុក/ម្តាយ និងកូនជាអចិន្ត្រៃយ៍ប៉ុណ្ណោះ ។

មាត្រា ៣

អនុសញ្ញានេះលែងអនុវត្តបានទៅទៀត បើការព្រមព្រៀងដែលបញ្ជាក់នៅក្នុងមាត្រា១៧ អនុកថាខ័ណ្ឌគ មិនបានធ្វើមុនពេលកុមារឈានដល់អាយុដប់ប្រាំបីឆ្នាំ ។

## ជំពូក ២

## លក្ខខណ្ឌតម្រូវ សំរាប់សុំកូនអន្តរប្រទេស

មាត្រា ៤

សុំកូនដែលស្ថិតក្នុងវិសាលភាពនៃអនុសញ្ញានេះ ត្រូវកើតមានឡើងលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដើម :

(ក)	បានកំណត់ថាកុមារមានលក្ខណៈអាចសុំយកទៅចិញ្ចឹមបាន

(ខ)	បានសំរេចថា សុំកូនអន្តរប្រទេសជាឧត្តមប្រយោជន៍របស់កុមារ បន្ទាប់ពីបានពិចារណាដិតដល់នូវលទ្ធភាពនៃការទុកដាក់កុមារនោះនៅក្នុងរដ្ឋដើម

(គ)	បានធានាថា

(១) ជន ស្ថាប័ន និង អាជ្ញាធរដែលចាំបាច់ត្រូវយល់ព្រមលើសុំកូនត្រូវបានពិគ្រោះយោបល់ បើជាការចាំបាច់ ហើយត្រូវបានជូនពត៌មានឱ្យបានដឹងដោយត្រឹមត្រូវអំពីផលប៉ះពាល់នៃការយល់ព្រមរបស់គេ ជាពិសេសឱ្យដឹងថាតើសុំកូននោះនឹងនាំឱ្យមានការបញ្ចប់ទំនាក់ទំនងរវាងកុមារ និងគ្រួសារកំណើតរបស់គេ ឬយ៉ាងណា

(២) ជន ស្ថាប័ន និងអាជ្ញាធរនោះផ្តល់ការយល់ព្រមរបស់ខ្លួនដោយសេរី តាមរយៈទម្រង់ ដែលច្បាប់តម្រូវ និងមានលិខិតបញ្ជាក់ ឬធ្វើជាភស្តុតាង

(៣) ការយល់ព្រមទាំងនោះ មិនមែនញ៉ាំងឱ្យមានឡើងដោយសារការចាយវាយប្រាក់កាស ឬការទូទាត់គ្នាតាមបែបណាមួយឡើយ និងមិនត្រូវបានដកវិញឡើយ ។ ហើយនិង

(៤) ការយល់ព្រមរបស់ម្តាយត្រូវបានផ្តល់តែបន្ទាប់ពីកូនកើតរួចហើយប៉ុណ្ណោះ ក្នុងករណីដែលមានការតម្រូវឱ្យម្តាយយល់ព្រម ។ ហើយនិង

(ឃ) បានធានា បន្ទាប់ពីបានគិតដល់អាយុ និងកំរិតនៃមជ្ឈឹមវ័យរបស់កុមារ ថា

(១) កុមារនោះត្រូវបានពិគ្រោះយោបល់ និងត្រូវបានប្រាប់ឱ្យដឹងត្រឹមត្រូវអំពីផលនៃសុំកូន និងអំពីការយល់ព្រមរបស់គេចំពោះសុំកូន ក្នុងករណីតម្រូវឱ្យមានការយល់ព្រមបែបនេះ

(២) មានការយកចិត្តទុកដាក់ដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារ

(៣) ការយល់ព្រមចំពោះសុំកូន ក្នុងករណីតម្រូវឱ្យមានការយល់ព្រមបែបនេះ ត្រូវបានផ្តល់ដោយសេរីតាមទម្រង់ដែលច្បាប់តម្រូវ និង បញ្ជាក់ ឬផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ហើយនិង

(៤) ការយល់ព្រមនោះមិនមែនញ៉ាំងឱ្យកើតឡើងដោយសារការចាយវាយប្រាក់កាស ឬការទូទាត់គ្នាតាមបែបណាមួយឡើយ ។

មាត្រា ៥

សុំកូននៅក្នុងវិសាលភាពនៃអនុសញ្ញានេះ ត្រូវកើតមានឡើងលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួល

(ក) បានធានាថា អនាគតឪពុកម្តាយចិញ្ចឹមនោះ មានគុណសម្បត្តិត្រឹមត្រូវ និងសមស្របអាចយកកូនមកចិញ្ចឹមបាន

(ខ) បានធានាថា អនាគតឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានពិគ្រោះយោបល់ បើជាការចាំបាច់ ។ ហើយនិង

(គ) បានសំរេចថា កុមារនោះត្រូវបាន ឬ នឹងត្រូវបានអនុញ្ញាតឱ្យចូល និង រស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ ។

## ជំពូក ៣

## អាជ្ញាធរមជ្ឈឹម និង អង្គការដែលទទួលសាល់ជាផ្លូវការ

មាត្រា ៦

១) រដ្ឋចុះហត្ថលេខាមួយត្រូវចាត់តាំងអាជ្ញាធរមជ្ឈឹម ដើម្បីបំពេញករណីយកិច្ចដែលអនុសញ្ញានេះដាក់បង្គាប់លើអាជ្ញាធរទាំងនោះ ។

២) រដ្ឋសហព័ន្ធ រដ្ឋដែលមានប្រព័ន្ធច្បាប់លើសពីមួយ ឬ រដ្ឋដែលមានដែនដីស្វយ័តត្រូវមានសេរីភាពតែងតាំងអាជ្ញាធរមជ្ឈឹមលើសពីមួយ និង បញ្ជាក់សមត្ថកិច្ចដែនដី ឬ សមត្ថកិច្ចបុគ្គលនៃមុខងាររបស់អាជ្ញាធរនោះ ។ ក្នុងករណីរដ្ឋមួយបានតែងតាំងអាជ្ញាធរមជ្ឈឹមលើសពីមួយ រដ្ឋនោះត្រូវចង្អុលប្រាប់អាជ្ញាធរមជ្ឈឹមណាដែលគេអាចបញ្ជូនពត៌មានទៅអាជ្ញាធរមជ្ឈឹមសមស្របនៅក្នុងរដ្ឋនោះ ។

មាត្រា ៧

១) អាជ្ញាធរមជ្ឈឹមទាំងឡាយត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក ហើយត្រូវលើកស្ទួយសហប្រតិបត្តិការក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋរបស់ខ្លួន ដើម្បីការពារកុមារ និងដើម្បី ធ្វើឱ្យបានសំរេចទិសដៅដទៃទៀតនៃអនុសញ្ញានេះ ។

២) អាជ្ញាធរមជ្ឈឹមទាំងឡាយត្រូវចាត់វិធានការដោយផ្ទាល់ដើម្បី

(ក) ផ្តល់ពត៌មានអំពីច្បាប់នៃរដ្ឋទាំងឡាយដែលពាក់ព័ន្ធនឹងសុំកូន និង ពត៌មានដទៃទៀតដូចជាស្ថិតិ និងទម្រង់ជាបទដ្ឋាន ។

(ខ) អាជ្ញាធរមជ្ឈឹមនីមួយៗបានដឹងទៅវិញទៅមកអំពីប្រតិបត្តិការនៃអនុសញ្ញានេះហើយ បើអាចធ្វើទៅបានកំចាត់ចោលឧបសគ្គទាំងឡាយនៃការអនុវត្តន៍អនុសញ្ញានេះ ។

មាត្រា ៨

អាជ្ញាធរមជ្ឈឹមទាំងឡាយ ដោយផ្ទាល់ក្តី ឬ តាមរយៈអាជ្ញាធរសាធារណៈក្តី ត្រូវចាត់វិធានការទាំងអស់ដែលសមស្របដើម្បីទប់ស្កាត់ការកេងយកចំណេញមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ ឬ ការកេងយកចំណេញប្រភេទដទៃទៀតដែលទាក់ទងនឹងសុំកូន ហើយនិងដើម្បីបន្ទុចបង្អាក់ការអនុវត្តន៍ទាំងអស់ដែលផ្ទុយនឹងទិសដៅនៃអនុសញ្ញានេះ ។

មាត្រា ៩

អាជ្ញាធរមជ្ឈឹមទាំងឡាយ ដោយផ្ទាល់ក្តី ឬតាមរយៈអាជ្ញាធរសាធារណៈក្តី ឬអង្គការដែលបានទទួលស្គាល់ត្រឹមត្រូវជាផ្លូវការក្តីនៅក្នុងរដ្ឋរបស់ខ្លួន ត្រូវចាត់វិធានការទាំងអស់ដែលសមស្របជាពិសេសដើម្បី

(ក) ជួយសំរួល ប្រតិបត្តិតាម និងជំរុញនីតិវិធីឱ្យបានលឿនដើម្បីឱ្យបានការអនុញ្ញាតសុំកូន

(ខ) លើកស្ទួយការបង្កើតសេវាកម្មផ្តល់ការពិគ្រោះខាងសុំកូន និងសេវាកម្មក្រោយពេលសុំកូននៅក្នុងរដ្ឋរបស់ខ្លួន

(គ) ផ្តល់របាយការណ៍វាយតម្លៃទូទៅដល់គ្នាទៅវិញទៅមក អំពីបទពិសោធន៍នៃការសុំកូនអន្តរប្រទេស ។

(ឃ) ឆ្លើយតបក្នុងករណីច្បាប់នៃរដ្ឋរបស់ខ្លួនអនុញ្ញាត ចំពោះសេចក្តីស្នើសុំដែលមានហេតុផលពីអាជ្ញាធរមជ្ឈឹមដទៃទៀត ឬ អាជ្ញាធរសាធារណៈដែលចង់បានពត៏មានអំពីស្ថានការណ៍ពិសេសណាមួយនៃសុំកូន ។

មាត្រា ១០

ការទទួលស្គាល់ជាផ្លូវការត្រូវផ្តល់ឱ្យ និងរក្សាការទទួលស្គាល់នោះបានចំពោះតែអង្គការណា ដែលបង្ហាញសមត្ថភាពរបស់គេក្នុងការអនុវត្តន៍ត្រឹមត្រូវនូវភារកិច្ចដែលគេបានទទួល ។

មាត្រា ១១

អង្គការដែលបានទទួលស្គាល់ជាផ្លូវការត្រូវ

(ក) បំរើតែទិសដៅមិនរកកំរៃស្របទៅតាមលក្ខខ័ណ្ឌនិងក្នុងកំរិតព្រដែនណា ដែលអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួលស្គាល់នោះបានកំណត់ឱ្យ

(ខ) បានដឹកនាំដោយមនុស្ស និងមានបុគ្គលិកដែលមានគុណសម្បត្តិយោលទៅលើបទដ្ឋានសីលធម៌របស់អ្នកដឹកនាំ និង បុគ្គលិកទាំងនោះ និងដោយសារការហ្វឹកហ្វឺន ឬ បទពិសោធន៍ការងារនៅក្នុងវិស័យសុំកូនក្រៅប្រទេស ។ និង

(គ) ស្ថិតក្រោមការត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ លើសមាសភាពប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ នៃអង្គការនោះ ។

មាត្រា ១២

អង្គការដែលបានទទួលស្គាល់ជាផ្លូវការនៅក្នុងរដ្ឋចុះកិច្ចសន្យាមួយអាចបំពេញនាទីនៅក្នុងរដ្ឋចុះហត្ថលេខាមួយទៀតបាន លុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទាំងពីរបានអនុញ្ញាតឱ្យធ្វើដូច្នេះ ។

មាត្រា ១៣

រដ្ឋចុះហត្ថលេខានីមួយៗត្រូវជូនពត៌មានទៅការិយាល័យអចិន្ត្រៃយ៍នៃសន្និសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនអំពីការចាត់តាំងអាជ្ញាធរមជ្ឈឹម ហើយក្នុងករណីសមស្រប អំពីទំហំនៃមុខងាររបស់អាជ្ញាធរនោះ ព្រមទាំងឈ្មោះ និងអាស័យដ្ឋាននៃអង្គការដែលទទួលស្គាល់ជាផ្លូវការ ។

## ជំពូក ៤

## លក្ខខណ្ឌផ្នែកនីតិវិធីសំរាប់សុំកូនអន្តរប្រទេស

មាត្រា ១៤

ជនដែលមានទីលំនៅជាប្រចាំនៅក្នុងរដ្ឋចុះហត្ថលេខាមួយ ដែលប្រាថ្នាចង់យកកុមារម្នាក់ដែលមានលំនៅជាប្រចាំនៅក្នុងរដ្ឋចុះហត្ថលេខាណាមួយទៀតទៅចិញ្ចឹម ត្រូវដាក់ពាក្យជាមួយអាជ្ញាធរមជ្ឈឹមនៅក្នុងរដ្ឋជាទីលំនៅប្រចាំរបស់ខ្លួន ។

មាត្រា ១៥

១) ប្រសិនបើអាជ្ញាធរមជ្ឈឹមនៃរដ្ឋទទួលពេញចិត្តថាអ្នកដាក់ពាក្យនោះមានលក្ខណៈសម្បត្តិ និង អាចសមស្របអាចយកមកចិញ្ចឹមបាន អាជ្ញាធរមជ្ឈឹមនោះត្រូវរៀបចំរបាយការណ៍មួយដោយរួមបញ្ចូលពត៌មានអំពីអត្តសញ្ញាណ លក្ខណៈសម្បត្តិ និងភាពសមស្របអាចសុំកូនបាន ប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ និង ប្រវត្តិផ្នែកពេទ្យ បរិយាកាសសង្គម ហេតុផលសុំកូន សមត្ថភាពដើម្បីយកកូនពីប្រទេសមួយទៀតមកចិញ្ចឹមរបស់អ្នកដាក់ពាក្យទាំងនោះ ព្រមទាំងចរិតលក្ខណៈនៃកូនដែលគេនឹងយកមកបីបាច់រក្សា ។

២) អាជ្ញាធរមជ្ឈឹមត្រូវផ្ញើរបាយការណ៍ទៅឱ្យអាជ្ញាធរមជ្ឈឹមនៃរដ្ឋដើម ។

មាត្រា ១៦

១) បើអាជ្ញាធរមជ្ឈឹមនៃរដ្ឋដើមពេញចិត្តថា កូននោះមានលក្ខណៈអាចសុំយកទៅចិញ្ចឹមបាន អាជ្ញាធរនោះត្រូវ

(ក) រៀបចំរបាយការណ៍មួយដោយរួមបញ្ចូលពត៌មានអំពីអត្តសញ្ញាណ ភាពអាចយកទៅចិញ្ចឹមបាន ប្រវត្តិ បរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិផ្នែកពេទ្យ រួមទាំងប្រវត្តិផ្នែកពេទ្យរបស់គ្រួសារក្មេងផង និង សេចក្តីត្រូវការពិសេសរបស់ក្មេង ។

(ខ) ធ្វើការពិចារណាដិតដល់លើការចិញ្ចឹមបីបាច់កូន និង ប្រវត្តិជាតិពន្ធ សាសនា និងវប្បធម៌របស់កូននោះ ។

(គ) ធានាថា ការយល់ព្រមត្រូវបានស្របនឹងមាត្រា ៤ ។ ហើយនិង

(ឃ) សំរេចថា តើការទុកដាក់កូនតាមការស្នើសុំនោះស្ថិតក្នុងឧត្តមប្រយោជន៍របស់ក្មេងដែរឬទេ ដោយសំអាងជាពិសេសលើរបាយការណ៍ទាក់ទងនឹងក្មេង និងអនាគតឪពុកម្តាយចិញ្ចឹម ។

២) អាជ្ញាធរមជ្ឈឹមនៃរដ្ឋដើមត្រូវបញ្ជូនឱ្យអាជ្ញាធរនៃរដ្ឋទទួលនូវរបាយការណ៍របស់ខ្លួនអំពីកុមារភស្តុតាងបានការយល់ព្រមជាចាំបាច់ និង ហេតុផលនៃការសំរេចរបស់ខ្លួនស្តីពីការឱ្យសុំកូននោះដោយយកចិត្តទុកដាក់មិនបញ្ចេញឱ្យដឹងអត្តសញ្ញាណនៃម្តាយ និងឪពុក ប្រសិនបើអត្តសញ្ញាណនេះមិនអាចបញ្ចេញឱ្យដឹងបាននៅក្នុងរដ្ឋដើម ។

មាត្រា ១៧

សេចក្តីសំរេចណាមួយនៅក្នុងរដ្ឋដើមដែលថា កុមារម្នាក់គួរតែបានផ្ទុកផ្តាក់ជាមួយអនាគត ឪពុកម្តាយចិញ្ចឹមនោះអាចធ្វើបានលុះត្រាណាតែ

(ក) អាជ្ញាធរមជឹមនៃរដ្ឋនោះបានធានាថាអនាគតឪពុកម្តាយចិញ្ចឹមព្រមព្រៀង

(ខ) អាជ្ញាធរនៃរដ្ឋទទួលបានយល់ព្រមលើសេចក្តីសំរេចនោះ ក្នុងករណីច្បាប់នៃរដ្ឋនោះ ឬ អាជ្ញាធរមជ្ឈឹមនៃរដ្ឋដើមតម្រូវឱ្យមានការយល់ព្រមបែបនោះ

(គ) អាជ្ញាធរមជ្ឈឹមនៃរដ្ឋទាំងពីរបានព្រមព្រៀងគ្នាថា សុំកូនអាចប្រព្រឹត្តទៅបាន ។ ហើយនិង

(ឃ) អាជ្ញាធរមជ្ឈឹមនៃរដ្ឋដើមបានសំរេចស្របតាមមាត្រា ៥ថា អនាគតឪពុកម្តាយចិញ្ចឹមមានគុណសម្បត្តិនិងសមនឹងយកកូនទៅចិញ្ចឹមបាន ហើយកូននោះត្រូវបាន ឬ នឹងត្រូវបានអនុញ្ញាតឱ្យចូលនិងរស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋទទួល ។

មាត្រា ១៨

អាជ្ញាធរមជ្ឈឹមនៃរដ្ឋទាំងពីរត្រូវចាត់វិធានការជាចាំបាច់ ដើម្បីបានការអនុញ្ញាតឱ្យកុមារចាកចេញពីរដ្ឋដើម និងចូល និងរស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋទទួល ។

មាត្រា ១៩

១) ការផ្ទេរកុមារទៅរដ្ឋទទួលអាចអនុវត្តបាន លុះត្រាតែលក្ខខ័ណ្ឌទាំងឡាយនៃមាត្រា ១៧ ត្រូវបានបំពេញ។

២) អាជ្ញាធរមជ្ឈឹមនៃរដ្ឋទាំងពីរត្រូវធានាថា ការផ្ទេរនេះធ្វើនៅក្នុងកាលៈទេសៈធានាសន្តិសុខ និងសមស្របហើយប្រសិនបើអាចធ្វើបានដោយមានការជូនដំណើរនៃឪពុកម្តាយចិញ្ចឹម ឬ អនាគតឪពុកម្តាយចិញ្ចឹម ។

៣) បើការផ្ទេរកុមារនោះមិនបានធ្វើឡើងទេនោះ របាយការណ៍ដែលបានពោលនៅក្នុងមាត្រា ១៥ និង ១៦ ត្រូវផ្ញើត្រឡប់មកឱ្យអាជ្ញាធរដែលបញ្ជូនរបាយការណ៍នោះវិញ ។

មាត្រា ២០

អាជ្ញាធរមជ្ឈឹមត្រូវឱ្យពត៌មានគ្នាទៅវិញទៅមកឱ្យបានដឹងជានិច្ចអំពីដំណើរការសុំកូន និង វិធានការណ៍ដើម្បីធ្វើឱ្យសុំកូននេះបានចប់សព្វគ្រប់ ព្រមទាំងអំពីដំណើរជឿនលឿននៃការទុកដាក់ក្មេង បើមានការតម្រូវឱ្យមានរយៈពេលសាកល្បង ។

មាត្រា ២១

១) ក្នុងករណីសុំកូនត្រូវកើតមានបាននៅពេលក្រោយ រដ្ឋទទួល ហើយអាជ្ញាធរមជ្ឈឹមនៃរដ្ឋនោះយល់ឃើញថា ការទុកដាក់កូនបន្តទៅទៀតជាមួយនឹងអនាគតឪពុកម្តាយចិញ្ចឹម មិនបំរើឧត្តមប្រយោជន៍របស់កុមារ អាជ្ញាធរមជ្ឈឹមនោះត្រូវចាត់វិធានការចាំបាច់ ដើម្បីការពារកុមារ ជាពិសេស

(ក) ធ្វើយ៉ាងណាឱ្យបានដកកុមារពីអនាគតឪពុកម្តាយចិញ្ចឹម ហើយរៀបចំឱ្យមានការបីបាច់បណ្តោះអាសន្ន ។

(ខ) ដោយពិគ្រោះជាមួយអាជ្ញាធរមជ្ឈឹមនៃរដ្ឋដើមរៀបចំដោយគ្មានបង្អង់ឱ្យមានការទុកដាក់កុមារនេះជាថ្មី ក្នុងឋានៈសុំកូនដដែល ឬបើរបៀបនេះមិនសមស្របទេនោះ រៀបចំឱ្យមានមធ្យោបាយជំនួស ដើម្បីបីបាច់កុមារក្នុងរយៈពេលវែង ។ សុំកូនមិនត្រូវកើតមានទេ រហូតទាល់តែអាជ្ញាធរមជ្ឈឹមនៃរដ្ឋដើមបានទទួលពត៌មានត្រឹមត្រូវទាក់ទងនឹងអនាគតឪពុកម្តាយចិញ្ចឹមថ្មី ។

(គ) មធ្យោបាយចុងក្រោយបង្អស់គឺ ត្រូវរៀបចំបញ្ជូនកុមារទៅរដ្ឋដើមវិញ បើផលប្រយោជន៍របស់កុមារតម្រូវឱ្យធ្វើដូច្នោះ ។

២) ដោយយោលជាពិសេសទៅលើអាយុ និង កំរិតមជ្ឈឹមវ័យរបស់កុមារ កុមារត្រូវតែពិគ្រោះយោបល់ ហើយក្នុងករណីសមស្របគេត្រូវតែបានការយល់ព្រមពីកុមារ ទាក់ទងនឹងវិធានការដែលចាត់តាមមាត្រានេះ ។

មាត្រា ២២

១) មុខងាររបស់អាជ្ញាធរមជ្ឈឹមនៅក្រោមជំពូកនេះ អាចបំពេញដោយអាជ្ញាធរសាធារណៈ ឬ អង្គការដែលបានទទួលស្គាល់ជាផ្លូវការក្រោមជំពូកទី៣ ក្នុងកំរិតដែលអនុញ្ញាតដោយច្បាប់នៃរដ្ឋរបស់អាជ្ញាធរនោះ ។

២) រដ្ឋចុះកិច្ចសន្យាណាមួយអាចប្រកាសចំពោះមន្ទីរដឹកលំអនុសញ្ញានេះថា មុខងារនៃអាជ្ញាធរមជ្ឈឹមនៅក្រោមមាត្រា ១៥ និង ២១ អាចបំពេញបានផងដែរនៅក្នុងរដ្ឋនោះ ដោយមានការត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ ដោយអង្គការ ឬ ជនដែល

(ក) បំពេញតាមលក្ខខ័ណ្ឌសុចរិតធម៌ សមត្ថភាពខាងវិជ្ជាជីវៈ ការពិសោធន៍ និងភាពទទួលខុសត្រូវចំពោះរដ្ឋនោះ ។ ហើយនិង

(ខ) មានគុណសម្បត្តិដោយសារបទដ្ឋានសីលធម៌ និងដោយសារការហ្វឹកហ្វឺន ឬ បទពិសោធន៍ធ្វើការក្នុងវិស័យសុំកូនអន្តរប្រទេស ។

៣) រដ្ឋចុះហត្ថលេខាមួយដែលធ្វើសេចក្តីប្រកាសដូចបានថ្លែងក្នុង កថាខ័ណ្ឌ២ ត្រូវឱ្យការិយាល័យអចិន្ត្រៃយ៍នៃសន្និសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនបានដឹងអំពីឈ្មោះ និង អាស័យដ្ឋាននៃអង្គការ និង ជនទាំងនេះ ។

៤) រដ្ឋចុះហត្ថលេខាណាមួយអាចប្រកាសចំពោះមន្ទីរតំកល់អនុសញ្ញានេះថា ការសុំយកទៅចិញ្ចឹមនូវកូនជានិវាសនជនប្រចាំនៅក្នុងដែនដីរបស់ខ្លួន អាចកើតមានឡើងបាន លុះត្រាណាតែមុខងារនៃអាជ្ញាធរមជ្ឈឹម ត្រូវបានបំពេញស្របតាមកថាខ័ណ្ឌ១ ។

៥) ថ្វីបើមានការប្រកាសណាមួយស្របតាមកថាខ័ណ្ឌ២ក្តី របាយការណ៍ដែលពោលនៅក្នុងមាត្រា ១៥ និង ១៦ នូវរាល់ករណីត្រូវតែបានរៀបចំនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរមជ្ឈឹម ឬអាជ្ញាធរដទៃទៀត ឬ អង្គការនានាស្របតាមកថាខ័ណ្ឌ១ ។

## ជំពូកទី ៥
## ការទទួលសំគាល់ និង ផលនៃការសុំកូន

មាត្រា ២៣

១) ការសុំកូនដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសុំកូនថាបានធ្វើឡើងស្របតាមអនុសញ្ញានេះ ត្រូវតែបានទទួលស្គាល់ជាស្វ័យប្រវត្តិដោយច្បាប់នៅក្នុងរដ្ឋចុះហត្ថលេខាដទៃ១ទៀត ។ លិខិតបញ្ជាក់នោះ ត្រូវដៅបញ្ជាក់ពេលវេលា និង អ្នកណាដែលផ្តល់ការព្រមព្រៀងស្របតាម មាត្រា ១៧ កថាខ័ណ្ឌគ ។

២) រដ្ឋចុះហត្ថលេខានីមួយ១ នៅពេលចុះហត្ថលេខា ពេលធ្វើសច្ចាប័ន ទទួលយក យល់ព្រម ឬចូលជាសមាជិកត្រូវផ្តល់ដំណឹងដល់មន្ទីរតំកល់អនុសញ្ញានេះអំពីអត្តសញ្ញាណ និងមុខងារនៃអាជ្ញាធរដែលមានសមត្ថកិច្ចនៅក្នុងរដ្ឋនោះ ដើម្បីធ្វើការបញ្ជាក់នោះ ។ រដ្ឋនោះក៏ត្រូវផ្តល់ដំណឹងដល់មន្ទីរតំកល់ដែរ អំពីការកែប្រែ ការតែងតាំងអាជ្ញាធរទាំងនេះ ។

មាត្រា ២៤

ការទទួលស្គាល់ស្មុំកូនអាចបដិសេធបាននៅក្នុងរដ្ឋចុះហត្ថលេខាមួយ លុះត្រាណាតែស្មុំកូននោះ ផ្ទុយជាក់ស្តែងនឹងទស្សនៈសាធារណៈនៃរដ្ឋនោះ ដោយពិចារណាដល់ឧត្តមប្រយោជន៍របស់កុមារ ។

មាត្រា ២៥

រដ្ឋដែលចុះហត្ថលេខាអាចប្រកាសចំពោះមន្ទីរតំកល់អនុសញ្ញាថា ខ្លួននឹងមិនជាប់កាតព្វកិច្ចនៅក្រោមអនុសញ្ញានេះ ដើម្បីទទួលស្គាល់ស្មុំកូនដែលធ្វើស្របតាមការព្រមព្រៀងមួយដែលបានសំរេចឡើងដោយការអនុវត្តន៍មាត្រា ៣៩ កថាខ័ណ្ឌ១ ។

មាត្រា ២៦

១) ការទទួលស្គាល់ស្មុំកូនរួមបញ្ចូលការទទួលស្គាល់ :

(ក) ទំនាក់ទំនងផ្លូវច្បាប់ជា ឪពុក/ម្តាយ និងកូន រវាងកូន និងឪពុកម្តាយចិញ្ចឹមរបស់កុមារនោះ ។

(ខ) ការទទួលខុសត្រូវផ្នែកមេបានៃឪពុកម្តាយចិញ្ចឹមរបស់កុមារ ។

(គ) ការបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ដែលមានពីមុនមក រវាងកូន និងម្តាយ និងឪពុករបស់កុមារ បើស្មុំកូននោះ ត្រូវបានធ្វើឡើង ។

២) ក្នុងករណីដែលស្មុំកូនមានផលបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ ដែលមានពីមុនមករវាងឪពុកម្តាយ និងកូន កុមារត្រូវទទួលបាននៅក្នុងរដ្ឋទទួល និង នៅក្នុងរដ្ឋចុះហត្ថលេខាដទៃទៀតដែលទទួលស្គាល់ស្មុំកូននូវសិទ្ធិស្មើគ្នា និងសិទ្ធិដែលកើតមកពីស្មុំកូនដែលមានផលដូច្នេះ នៅក្នុងរដ្ឋនីមួយៗនោះ ។

៣) កថាខ័ណ្ឌខាងមុនៗនេះ មិនត្រូវឱ្យប៉ះពាល់ដល់ការអនុវត្តន៍បញ្ញត្តិណាមួយដែលឱ្យអំណោយផលដល់កុមារច្រើនជាង ហើយដែលនៅជាធរមាននៅក្នុងរដ្ឋចុះហត្ថលេខាដែលទទួលស្គាល់ស្មុំកូន ។

មាត្រា ២៧

១) ក្នុងករណីស្មុំកូនដែលត្រូវបានអនុញ្ញាតនៅក្នុងរដ្ឋដើម មិនមានផលបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ដែលមានពីមុនមករវាងឪពុក/ម្តាយ និងកូនទេនោះ ស្មុំកូននោះអាចប្រែទៅជាស្មុំកូនមួយដែលមានផលដូច្នោះនៅក្នុងរដ្ឋទទួលដែលទទួលស្គាល់ស្មុំកូននៅក្រោមអនុសញ្ញានេះ :

(ក) បើច្បាប់នៃរដ្ឋទទួលអនុសញ្ញាឱ្យប្រែដូច្នេះ ។ និង

(ខ) បើការយល់ព្រមដូចបានពោលនៅក្នុងមាត្រា ៤ អនុកថាខ័ណ្ឌគ និង ឃ ត្រូវបានផ្តល់សំរាប់គោលបំណងនៃស្មុំកូននោះ ។

២)	មាត្រា ២៣ អនុវត្តចំពោះសេចក្ដីសំរេចប្រែស្មុំកូន ។

## ជំពូកទី ៦

## បទប្បញ្ញត្តិទូទៅ

មាត្រា ២៨

អនុសញ្ញានេះមិនមានផលប៉ះពាល់ដល់ច្បាប់ណាមួយនៃរដ្ឋដើមដែលតម្រូវថា ស្មុំកូនណាមួយដែលជានិវាសនជនជាប្រចាំនៅក្នុងរដ្ឋនោះ ត្រូវតែធ្វើនៅក្នុងរដ្ឋនោះទេ ឬដែលហាមឃាត់ការទុកកុមារនៅក្នុង ឬផ្ទេរកុមារទៅរដ្ឋទទួលមុនពេលស្មុំកូនទេ ។

មាត្រា ២៩

មិនត្រូវមានការជួបទាក់ទង រវាងអនាគតឪពុកម្ដាយចិញ្ចឹមរបស់កុមារ ឬ ជនដទៃទៀត ដែលបានបីបាច់រក្សាកុមារទេ រហូតទាល់តែលក្ខខណ្ឌនៃមាត្រា ៤ អនុកថាខ័ណ្ឌក ដល់ គ និងមាត្រា ៥ អនុកថាខ័ណ្ឌ ក បានបំពេញរួចសិន លើកលែងតែស្មុំកូននោះកើតមាននៅក្នុងគ្រួសារមួយ ឬ លើកលែងតែការជួបទាក់ទងនោះស្របតាមលក្ខខណ្ឌដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដើម ។

មាត្រា ៣០

១)	អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋចុះហត្ថលេខាត្រូវធានាថា ពត៌មានដែលខ្លួនរក្សាទុកទាក់ទងនឹងដើមកំណើតរបស់កុមារ ជាពិសេសពត៌មានទាក់ទងនឹងអត្តសញ្ញាណឪពុកម្ដាយរបស់កុមារ ព្រមទាំងប្រវត្តិផ្នែកពេទ្យត្រូវបានរក្សាការពារ ។

២)	អាជ្ញាធរមានសមត្ថកិច្ចទាំងនោះត្រូវធានាថាកុមារ ឬតំណាងរបស់កុមារមានសិទ្ធិទទួលបានពត៌មាននោះក្រោមការណែនាំដ៏សមស្រប ក្នុងកំរិតដែលច្បាប់នៃរដ្ឋនោះអនុញ្ញាត ។

មាត្រា ៣១

ដោយមិនធ្វើឱ្យប៉ះពាល់ដល់មាត្រា ៣០ ទិន្នន័យផ្ទាល់ខ្លួនដែលប្រមូលបាន ឬ ដែលត្រូវបានបញ្ជូនស្របតាមអនុសញ្ញានេះ ជាពិសេស ទិន្នន័យដូចបានពោលក្នុងមាត្រា ១៥ និង ១៦ ត្រូវប្រើប្រាស់សំរាប់តែគោលបំណងដែលប្រមូល ឬ បញ្ជូនប៉ុណ្ណោះ ។

មាត្រា ៣២

១)  គ្មានជនណាម្នាក់ទាញយកផលកំរៃផ្នែកហិរញ្ញវត្ថុ  ឬផលកំរៃដទៃទៀតពីសកម្មភាពទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

២)  មានតែសោហ៊ុយនិងប្រាក់ចំណាយ  រួមមានប្រាក់ឈ្នួលវិជ្ជាជីវៈសមរម្យរបស់ជនដែលពាក់ព័ន្ធក្នុងរឿងសុំកូនប៉ុណ្ណោះ ដែលអាចយកបាន ឬ ចំណាយបាន ។

៣)  នាយក អភិបាល និងនិយោជិតនៃអង្គការដែលពាក់ព័ន្ធក្នុងរឿងសុំកូនមិនត្រូវទទួលលាភការដែលខ្ពស់មិនសមរម្យទាក់ទងនឹងសេវាកម្មដែលខ្លួនបានផ្តល់ទេ ។

មាត្រា ៣៣

អាជ្ញាធរមានសមត្ថកិច្ចដែលឃើញថាបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះ មិនទាន់បានគោរព ឬមានយថាគ្រោះធ្ងន់ធ្ងរ ដែលខ្លួនអាចមិនគោរពបញ្ញត្តិនោះ ត្រូវជូនពត៏មានជាបន្ទាន់ដល់អាជ្ញាធរមជ្ឈឹមនៃរដ្ឋរបស់ខ្លួន ។ អាជ្ញាធរមជ្ឈឹមនេះ ត្រូវបានទទួលខុសត្រូវក្នុងការធានាថា វិធានការសមស្របត្រូវបានប្រកាន់យក ។

មាត្រា ៣៤

បើអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួលឯកសារស្នើសុំឱ្យបកប្រែឯកសារមួយនោះ អត្ថបទបកប្រែដែលបានបញ្ជាក់ថាស្របគ្នានឹងអត្ថបទដើម ហើយនោះត្រូវតែបានផ្តល់តាមការស្នើសុំ ។ លើកលែងតែបញ្ជាក់ផ្សេងទៀត សោហ៊ុយនៃការបកប្រែនោះត្រូវជាភារៈរបស់អនាគតឪពុកម្តាយចិញ្ចឹម ។

មាត្រា ៣៥

អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋហត្ថលេខីត្រូវចាត់ការដោយរួសរាន់នៅក្នុងដំណើរការសុំកូន ។

មាត្រា ៣៦

ទាក់ទងនឹងរដ្ឋមួយដែលមានប្រព័ន្ធច្បាប់ពីរ ឬ ច្រើនចំពោះរឿងសុំកូនដែលអនុវត្តនៅក្នុងដែនដីផ្សេងៗ :

(ក)  ការនិយាយថា ទីលំនៅជាប្រចាំនៅក្នុងរដ្ឋនោះ ត្រូវបកស្រាយថា គេចង់និយាយសំដៅដល់ទីលំនៅជាប្រចាំនៅក្នុងដែនដីមួយនៃរដ្ឋនោះ ។

(ខ)  ការនិយាយថា ច្បាប់នៃរដ្ឋនោះត្រូវបកស្រាយថា គេចង់និយាយសំដៅដល់ច្បាប់ជាធរមាននៅក្នុងដែនដីមួយដែលពាក់ព័ន្ធនៅក្នុងរដ្ឋនោះ ។

(គ) ការនិយាយថា អាជ្ញាធរមានសមត្ថកិច្ច ត្រូវអាជ្ញាធរសាធារណៈនៃរដ្ឋនោះ ត្រូវបកស្រាយថា គេចង់និយាយសំដៅដល់អាជ្ញាធរទាំងឡាយដែលត្រូវបានអនុញ្ញាតឱ្យបំពេញនាទីនៅក្នុងដែនដីមួយដែលពាក់ព័ន្ធនៅក្នុងរដ្ឋនោះ។

(ឃ) ការនិយាយដល់អង្គការដែលបានទទួលស្គាល់ជាផ្លូវការនៅក្នុងរដ្ឋនោះ ត្រូវបកស្រាយថាគេចង់និយាយសំដៅដល់អង្គការដែលបានទទួលស្គាល់ជាផ្លូវការនៅក្នុងដែនដីមួយដែលពាក់ព័ន្ធនៅក្នុងរដ្ឋនោះ ។

មាត្រា ៣៧

ទាក់ទងនឹងរដ្ឋមួយក្នុងរឿងសុំកូនមានប្រព័ន្ធច្បាប់ពីរ ឬលើសដែលអាចអនុវត្តបានលើប្រភេទមនុស្សផ្សេងគ្នា ការនិយាយដល់ប្រព័ន្ធច្បាប់មួយ ត្រូវបកស្រាយថា គេចង់និយាយដល់ប្រព័ន្ធច្បាប់ ដែលបញ្ជាក់ដោយច្បាប់នៃរដ្ឋនោះ។

មាត្រា ៣៨

រដ្ឋមួយដែលក្នុងនោះដែនដីចំណុះផ្សេងៗគ្នាមានវិធាននៃច្បាប់របស់ខ្លួនរៀងៗខ្លួនទាក់ទងនឹងរឿងសុំកូន មិនត្រូវជាប់កាតព្វកិច្ចត្រូវអនុវត្តអនុសញ្ញានេះទេ ក្នុងករណីដែលរដ្ឋមួយដែលមានប្រព័ន្ធច្បាប់រួមមិនជាប់កាតព្វកិច្ចត្រូវអនុវត្តអនុសញ្ញានេះ ។

មាត្រា ៣៩

១) អនុសញ្ញានេះមិនមានផលប៉ះពាល់ដល់ឧបករណ៍អន្តរជាតិណាមួយ ដែលរដ្ឋចុះហត្ថលេខាទាំងឡាយជាភាគីនៃឧបករណ៍នោះ ហើយឧបករណ៍នោះមានបញ្ញត្តិអំពីរឿងទាំងឡាយ ដែលគ្រប់គ្រងដោយអនុសញ្ញានេះ លើកលែងតែរដ្ឋជាភាគីនៃលិខិតុបករណ៍នោះបានធ្វើសេចក្តីប្រកាសផ្ទុយពីនេះ ។

២) រដ្ឋចុះហត្ថលេខាមួយអាចចុះកិច្ចព្រមព្រៀងជាមួយរដ្ឋចុះហត្ថលេខាមួយ ឬច្រើនក្នុងទិសដៅកែលំអការអនុវត្តន៍អនុសញ្ញានេះនៅក្នុងទំនាក់ទំនងគ្នាទៅវិញទៅមករវាងរដ្ឋទាំងនេះ ។ កិច្ចព្រមព្រៀងទាំងនេះ អាចដកអនុភាពតែពីបញ្ញត្តិនៃមាត្រា ១៥ ដល់ ១៦ និង ១៨ ដល់ ២១ ប៉ុណ្ណោះ ។ រដ្ឋដែលបានចុះកិច្ចព្រមព្រៀងត្រូវបញ្ជូនអត្ថបទកិច្ចព្រមព្រៀងនោះ ទៅមន្ទីរតំកល់អនុសញ្ញានោះ ។

មាត្រា ៤០

ការដាក់លក្ខខ័ណ្ឌលើការអនុវត្តន៍អនុសញ្ញានេះ មិនអាចអនុញ្ញាតបានទេ ។

មាត្រា ៤១

អនុសញ្ញានេះត្រូវអនុវត្តនៅគ្រប់ករណី កាលណាគេមិនទាន់បានទទួលពាក្យសុំសមស្របតាមមាត្រា ១៤ ក្រោយពីអនុសញ្ញានេះបានចូលជាធរមាននៅក្នុងរដ្ឋទទួល និង រដ្ឋដើម ។

មាត្រា ៤២

អគ្គលេខាធិការនៃសន្និសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនត្រូវកោះប្រជុំនៅក្នុងចន្លោះពេលទៀងទាត់នូវគណៈកម្មការពិសេស ដើម្បីពិនិត្យមើលឡើងវិញ ពីដំណើរការអនុវត្តន៍ជាក់ស្តែងនៃអនុសញ្ញានេះ ។

## ជំពូកទី ៧

## ខអវសាន្ស

មាត្រា ៤៣

១) អនុសញ្ញានេះត្រូវទុកចំហរអោយចុះហត្ថលេខាដោយរដ្ឋ ដែលជាសមាជិកនៃសន្និសិទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជននៅពេលសម័យប្រជុំលើកទី ១៧ និង ដោយរដ្ឋដទៃទៀតដែលបានចូលរួមក្នុងសម័យប្រជុំនោះ ។

២) អនុសញ្ញានេះត្រូវទទួលសច្ចាប័ន ទទួលយក និងយល់ព្រម ហើយឧបករណ៍នៃសច្ចាប័ន ការទទួលយក ឬការយល់ព្រម ត្រូវតំកល់ទុកជាមួយក្រសួងការបរទេសនៃព្រះរាជាណាចក្រហុល្លង់ នៅមន្ទីរតំកល់អនុសញ្ញានេះ ។

មាត្រា ៤៤

១) រដ្ឋដទៃទៀត អាចចូលជាសមាជិកនៃអនុសញ្ញាបន្ទាប់ពីអនុសញ្ញានេះបានចូលជាធរមានស្របតាមមាត្រា ៤៦ កថាខ័ណ្ឌ១ ។

២) ឧបករណ៍ចូលជាសមាជិកត្រូវតំកល់ទុកជាមួយមន្ទីរតំកល់អនុសញ្ញានេះ ។

៣) ការចូលជាសមាជិកនេះ មានអនុភាពចំពោះទំនាក់ទំនងរវាងរដ្ឋចូលជាសមាជិក និង រដ្ឋចុះហត្ថលេខាទាំងឡាយដែលមិនបានជំទាស់នឹងការចូលជាសមាជិក នៃរដ្ឋនោះក្នុងរយៈពេល ០៦ខែ បន្ទាប់ពីទទួលសេចក្តីជូនដំណឹងដូចមានពោលនៅក្នុងអនុកថាខ័ណ្ឌ ខ នៃមាត្រា ៤៨ ។ ការជំទាស់នោះក៏អាចធ្វើឡើងដោយរដ្ឋនានានៅពេលដែលរដ្ឋទាំងនោះ ផ្តល់សច្ចាប័នទទួលយក ឬ យល់ព្រមអនុសញ្ញាបន្ទាប់ពីការចូលជាសមាជិក ។ ការជំទាស់បែបនេះត្រូវជូនដំណឹងដល់មន្ទីរតំកល់ ។

មាត្រា ៤៥

១)	បើរដ្ឋមួយមានដែនដីពីរ ឬលើសនេះ ហើយដែនដីទាំងនោះមានប្រព័ន្ធច្បាប់ខុសៗគ្នា ដែលអនុវត្តចំពោះរឿងទាក់ទងនឹងរឿងក្នុងអនុសញ្ញានេះ ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិកអាចប្រកាសថា អនុសញ្ញានេះត្រូវលាតសន្ធឹងដល់ដែនដីទាំងអស់នៃរដ្ឋនោះ ឬត្រឹមតែដែនដីមួយ ឬច្រើនក្នុងចំណោមដែនដីទាំងអស់នោះ ហើយអាចកែប្រែ ប្រកាសនេះដោយជូនការប្រកាសមួយទៀតនៅពេលណាក៏បាន ។

២)	ការប្រកាសបែបនោះត្រូវជូនដំណឹងទៅមន្ទីរតំកល់អនុសញ្ញា ហើយត្រូវថ្លែងបញ្ជាក់ឱ្យបានជាក់ច្បាស់ថាដែនដីណាដែលអនុសញ្ញានេះអនុវត្ត ។

៣)	បើរដ្ឋមួយមិនបានធ្វើការប្រកាសតាមមាត្រានេះទេនោះ អនុសញ្ញានេះនឹងត្រូវលាតសន្ធឹងដល់ដែនដីទាំងអស់ ។

មាត្រា ៤៦

១)	អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទីមួយនៃខែបន្ទាប់ពីការផុតកំណត់រយៈពេលបីខែ បន្ទាប់ពីថ្ងៃតំកល់ឧបករណ៍ទីបីនៃសច្ចាប័ន ការទទួលយក ឬការយល់ព្រម ដែលបានពោលនៅក្នុងមាត្រា ៤៣ ។

២)	បន្ទាប់ពីនោះមក អនុសញ្ញានេះត្រូវចូលជាធរមាន

(ក)	ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ទទួលយក ឬ យល់ព្រមអនុសញ្ញានេះនៅពេលក្រោយមក ឬរដ្ឋនីមួយៗដែលចូលជាសមាជិកនៃអនុសញ្ញានេះ នៅថ្ងៃទីមួយនៃខែបន្ទាប់ពីការផុតកំណត់រយៈពេលបីខែ ចាប់ពីថ្ងៃតំកល់ឧបករណ៍សច្ចាប័នទទួលយក យល់ព្រម ឬចូលជាសមាជិក ។

(ខ)	ចំពោះដែនដីមួយដែលអនុសញ្ញានេះបានលាតសន្ធឹងទៅដល់ ស្របតាមមាត្រា៤៦ នៅថ្ងៃទីមួយនៃខែបន្ទាប់ពីការផុតកំណត់រយៈពេលបីខែ ចាប់ពីការជូនដំណឹងដូចបានពោលក្នុងមាត្រានោះ ។

មាត្រា ៤៧

១)	រដ្ឋជាសមាជិកនៃអនុសញ្ញានេះ អាចបដិសេធអនុសញ្ញានេះវិញដោយធ្វើលិខិតជូនដំណឹងដាក់ជូនទៅមន្ទីរតំកល់អនុសញ្ញា ។

២)	ការបដិសេធចូលជាធរមាននៅថ្ងៃទី ១នៃខែបន្ទាប់ពីផុតរយៈពេល ១២ខែគិតចាប់ពីថ្ងៃដែលមន្ត្រីតំកល់អនុសញ្ញាបានទទួលលិខិតជូនដំណឹង ។ ក្នុងករណីដែលលិខិតជូនដំណឹងបញ្ជាក់សូមអោយការបដិសេធអនុសញ្ញានេះចូលជាធរមាននៅក្នុងរយៈពេលយូរជាងនេះ ការបដិសេធនោះចូលជាធរមាននៅថ្ងៃដែលផុតរយៈពេលយូរជាងនោះ រាប់ចាប់ពីថ្ងៃដែលមន្ត្រីតំកល់អនុសញ្ញាបានទទួលលិខិតជូនដំណឹង ។

មាត្រា ៤៨

មន្ទីរតំកល់អនុសញ្ញាត្រូវជូនដំនឹងដល់រដ្ឋជាសមាជិកនៃសន្និសីទក្រុងឡាអេស្តីពីច្បាប់អន្តរជាតិឯកជន រដ្ឋដទៃទៀតដែលបានចូលរួមនៅក្នុងសម័យប្រជុំលើកទីដប់ប្រាំពីរ និង រដ្ឋដែលបានចូលជាភាគីស្របតាមមាត្រា៤៤ នូវ ពត៌មានដូចតទៅនេះ :

(ក) ហត្ថលេខា សច្ចាប័ន ការទទួលយក និង ការយល់ព្រមដូចមានយោងនៅក្នុងមាត្រា ៤៣

(ខ) ការសុំចូលជាភាគី និងការជំទាស់ចំពោះការចូលជាភាគីដូចមានយោងក្នុងមាត្រា ៤៤

(គ) កាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានស្របតាមមាត្រា ៤៦

(ឃ) ការប្រកាស និង ការចាត់តាំងដូចមានយោងក្នុងមាត្រា ២២ ២៣ ២៥ និង ៤៥

(ង) កិច្ចព្រមព្រៀងដូចមានយោងក្នុងមាត្រា ៣៩

(ច) ការបដិសេធដូចមានយោងក្នុងមាត្រា ៤៧ ។

ដើម្បីជាសាក្សីនៃអនុសញ្ញានេះ សាម៉ីជនដោយបានទទួលការអនុញ្ញាតត្រឹមត្រូវបានចុះហត្ថលេខាលើអនុសញ្ញានេះ ។ ធ្វើនៅទីក្រុងឡាអេ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ១៩៩៣ ជាភាសាអង់គ្លេស និងបារាំង ។ អត្ថបទទាំងពីរនេះមានតម្លៃយថាភូតស្មើគ្នា មានតែមួយច្បាប់ដែលត្រូវបានតំកល់ទុកនៅបណ្ណសារនៃរដ្ឋាភិបាលនៃព្រះរាជាណាចក្រហុល្លង់ ។ អត្ថបទ ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវត្រូវបញ្ជូនតាមរយៈផ្លូវទូតដល់រដ្ឋនីមួយៗ នៃរដ្ឋជាសមាជិកនៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជន នៅសម័យប្រជុំលើកទីដប់ប្រាំពីរ និង ដល់រដ្ឋនីមួយៗនៃរដ្ឋដទៃទៀតដែលបានចូលរួមនៅក្នុងសម័យប្រជុំនោះ ។